ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ២៨៦.........សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតរង្វាន់ប្រធានសម្រាប់ឆ្នាំ២០១៦ របស់អគ្គាធិការដ្ឋាន

### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និង អង្គការសាធារណៈរដ្ឋបាល



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញប្រកាសលេខ ០០៤ សហវ.ម.ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ២១១ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនី នៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ស្តីពីការបង្កើតនិងដាក់ឱ្យដំណើរការ អង្គភាពថវិកា របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធី ចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ
- បានឃើញប្រកាសលេខ ១៨៤១ សហវ.ប្រក ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិលើឥណទានថវិការជ្ជទេយ្យបុរេប្រទាន ជូនប្រធានអង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៣៣ សហវ.ប្រក ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការតែងតាំងរជ្ជទេយ្យករបុរេប្រទាន និងរជ្ជទេយ្យករបុរេប្រទានរងរបស់អង្គភាពថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញសេចក្តីណែនាំលេខ ០០៤ សហវ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីវិធាន និងនីតិវិធី នៃការរៀបចំ និងការអនុវត្តចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់ដំណើរការផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញសេចក្តីណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៥ ស្តីពីគោលការណ៍និងនីតិវិធីផ្ទៃក្នុងសម្រាប់ការអនុវត្តថវិកាកម្មវិធី របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើតរជ្ជទេយ្យបុរេប្រទានថវិកាជំពូក៦០ “ការទិញ” និង ជំពូក៦១ “សេវាកម្ម” នៅអគ្គាធិការដ្ឋាន សម្រាប់មុខសញ្ញាចំណាយ ដូចមានចែងក្នុងប្រការ៥ថ្មី នៃប្រកាសលេខ ៨២៩ សហវ.ប្រក ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋ បាលថ្នាក់ជាតិ។

តារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន ត្រូវបានកំណត់ជាឧបសម្ព័ន្ធ នៃប្រកាសនេះ។

**ប្រការ២.-**

ចំនួនទឹកប្រាក់មួយជុំបង្វិល នៃរជ្ជទេយ្យបុរេប្រទាន ត្រូវកំណត់ដូចក្នុងតារាងឧបសម្ព័ន្ធរជ្ជទេយ្យបុរេប្រទាន។

ប្រការ៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៤.-

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថាន ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាមីអង្គភាពថវិកា
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អគ្គធិការដ្ឋាន

តារាងឧបសម្ព័ន្ធវិទ្ធមានឥណទានថវិកាកម្មវិធីឆ្នាំ២០១៦
របស់អគ្គាធិការដ្ឋាន

(ឯកតាគិតជារៀល)

| ជំពូក | គណនី | អនុគណនី | រាយមុខចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៥ | ឥណទាន ដែលជ្រើសរើស | ឥណទាន វិជ្ជមានបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទាន១ជុំបង្វិល វិជ្ជមានបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ =២-៣ | ៥ = ៣/ ៤ជុំ | ៦= ៣/ ២ |
| | | | សរុបរួម | 737,900,000 | 694,400,000 | 635,080,000 | 59,320,000 | 158,770,000 | 91.5% |
| 60 | | | ការទិញ | 117,400,000 | 86,200,000 | 35,200,000 | 51,000,000 | 8,800,000 | 40.8% |
| | 6001 | | សម្ភារៈផ្គត់ផ្គង់ថែទាំ | 31,200,000 | - | - | - | - | #DIV/0! |
| | | 60015 | ប្រេងឥន្ធនៈនិងប្រេងរំអិល | 31,200,000 | | | - | - | |
| | 6002 | | សម្ភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល | 82,200,000 | 82,200,000 | 31,200,000 | 51,000,000 | 7,800,000 | 38.0% |
| | | 60021 | សម្ភារៈការិយាល័យនិងការបោះពុម្ព | 82,200,000 | 82,200,000 | 31,200,000 | 51,000,000 | 7,800,000 | 38.0% |
| | 6005 | | សម្ភារៈតូចតាច សង្ហារិម និងសម្ភារៈបរិក្ខារ | 4,000,000 | 4,000,000 | 4,000,000 | - | 1,000,000 | 100.0% |
| | | 60051 | សម្ភារៈនិងបរិក្ខារបច្ចេកទេស | 4,000,000 | 4,000,000 | 4,000,000 | - | 1,000,000 | 100.0% |
| 61 | | | សេវាកម្ម | 620,500,000 | 608,200,000 | 599,880,000 | 8,320,000 | 149,970,000 | 98.6% |
| | 6110 | | ទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយ | 12,300,000 | - | - | - | - | #DIV/0! |
| | | 61103 | ប្រជុំ សិក្ខាសាលា និងសន្និសីទ | 12,300,000 | | - | - | - | #DIV/0! |

| ជំពូក | គណនី | អនុគណនី | រាយមុខចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៥ | ឥណទាន ដែលស្រើសរើស | ឥណទាន រដ្ឋទេយ្យបុរេប្រទាន | ឥណទាន ទូទាត់ធម្មតា | ឥណទាន១ជំពូកមិល រដ្ឋទេយ្យបុរេប្រទាន | ភាគរយ |
|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤=២-៣ | ៥ = ៣/៤ជុំ | ៦=៣/២ |
| | 6112 | | ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស | 608,200,000 | 608,200,000 | 599,880,000 | 8,320,000 | 149,970,000 | 98.6% |
| | | 61121 | សោហ៊ុយដឹកជញ្ជូន | 118,500,000 | 118,500,000 | 117,300,000 | 1,200,000 | 29,325,000 | 99.0% |
| | | 61122 | សោហ៊ុយបេសកកម្ម | 64,400,000 | 64,400,000 | 63,480,000 | 920,000 | 15,870,000 | 98.6% |
| | | 61123 | សោហ៊ុយស្នាក់នៅ | 425,300,000 | 425,300,000 | 419,100,000 | 6,200,000 | 104,775,000 | 98.5% |

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី២៥ ខែ៥ ឆ្នាំ២០១៦
ឧ. អគ្គនាយក
អគ្គនាយកដ្ឋានរតនាគារជាតិ
អគ្គនាយករង
មុំញ បានសុវណ្ណអាតិច្ចសីលា

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី 11 ខែ 05 ឆ្នាំ២០១៦
អគ្គនាយក
អគ្គនាយកដ្ឋានថវិកា
គីម ចំរើន

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃទី ២៥ ខែ ឆ្នាំ២០១៦
អគ្គាធិការ
-រក វីរៈដេត

ថ្ងៃទី ខែ ឆ្នាំ២០១៦
រដ្ឋលេខាធិការប្រធានបុរេប្រទាន

បានឃើញ និងឯកភាព
ថ្ងៃទី២៦ ខែមិនា ឆ្នាំ២០១៦
រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អូន ព័ន្ធមុនីរ័ត្ន